បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

# ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

## ប.ស.ស. ឆ្នាំទី ១១
## លេខ ៣០ ឆ្នាំ២០២០




ធានាសន្តិសុខប្រាក់ចំណូល
រួមចំណែកកាត់បន្ថយភាពក្រីក្រ
លើកកម្ពស់ស្ថិរភាពសង្គម

ទំនាក់ទំនងឯបន្ទាន់
**១២៨៦**
**២៤ម៉ោង/៧ថ្ងៃ**

# ព្រឹត្តិបត្រព័ត៌មាន
# ប.ស.ស.



## មាតិកា


០១ ពិធីប្រកាសសមាសភាពក្រុមប្រឹក្សាភិបាល ប.ស.ស. ................០១
០២ ក្រុមប្រឹក្សាភិបាល ប.ស.ស. រៀបចំកិច្ចប្រជុំលើកទី១................០៣
០៣ ក្រុមប្រឹក្សាភិបាល ប.ស.ស. បន្តកិច្ចប្រជុំពិភាក្សាលើកទី២ .......០៥
០៤ ក្រុមប្រឹក្សាភិបាល ប.ស.ស. បានបើកកិច្ចប្រជុំពិភាក្សាលើ.........០៧
០៥ ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បានបន្តបើកកិច្ចប្រជុំពិភាក្សា......០៩
០៦ កម្មវិធីទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្រ្តតាម............១១
០៧ បេឡាជាតិសន្តិសុខសង្គម រៀបចំកិច្ចប្រជុំប្រចាំខែដំបូង ............១២
០៨ អគ្គនាយក ប.ស.ស. ទទួលជួបពិភាក្សាការងារ ជាមួយដៃគូ.......១៤
០៩ អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ នៅតែបន្តកិច្ចសហការជួយគាំទ្រ..១៦
១០ ប.ស.ស. រៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីបច្ចុប្បន្នភាពការងារ.........១៨
១១ វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ទូទៅនៃរបបសន្តិសុខ.........២០
១២ វគ្គបណ្តុះបណ្តាលស្តីពី"របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" .២២
១៣ បេឡាជាតិសន្តិសុខសង្គមកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ....២៤
១៤ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃ ប.ស.ស. កម្ពុជាបានចូលរួម..២៩
១៥ សន្និសីទស្តីពី ការកសាងត្រឡប់មកវិញឲ្យកាន់តែប្រសើរ..........៣០
១៦ កិច្ចប្រជុំពិភាក្សា កម្មវិធី NSSF Member App សម្រាប់សមាជិក..៣១
១៧ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គណៈកម្មាធិការរៀបចំការ...៣២
១៨ នៅពេលឆាប់ៗខាងមុខនេះ បេឡាជាតិសន្តិសុខសង្គម នឹងដាក់..៣៤
១៩ កិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចគាំពារសង្គមដើម្បី..........៣៦
២០ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស នៃ ប.ស.ស. កម្ពុជា ចូលរួម.....៣៧
២១ តើការបរិភោគចេកមុនចូលដេកនៅពេលយប់អាចល្អយ៉ាងដូច....៣៨
២២ ភិក្ខុ វជិរប្បញ្ញោ គូ សុភាព គំនិតអប់រំ.................................... ៣៩









## រចនាសម្ព័ន្ធព្រឹត្តិបត្រ

### ឯកឧត្តម អ៊ុក សមវិទ្យា
### អគ្គនាយក ប.ស.ស.

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក ឃុន វិចិត្រ |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា រ៉ាត់ ម៉ាលីកា |
| | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| ផ្នែកការិកុំព្យូទ័រ | លោក យង់ សុខន |
| | លោក តា ម៉េងហាក់ |
| | លោក អ៊ុង ស៊ីខឿ |



# ពិធីប្រកាសសមាសភាពក្រុមប្រឹក្សាភិបាល ប.ស.ស. អាណត្តិទី១

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ក្នុងពិធីប្រកាសសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១ នាថ្ងៃព្រហស្បតិ៍ ទី៦ ខែសីហា ឆ្នាំ២០២០ បានផ្តល់អនុសាសន៍លើកទឹកចិត្ត ដល់មន្ត្រី ប.ស.ស. គ្រប់ជាន់ថ្នាក់ ពិសេសក្រុមប្រឹក្សាភិបាល ប.ស.ស. អាណត្តិចាស់ ដែលកន្លងមកបានខិតខំបំពេញការងារបានយ៉ាងល្អប្រសើរ។

ជាមួយគ្នានេះដែរ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ក៏បានក្រើនរំលឹកដល់សមាជិកក្រុមប្រឹក្សាភិបាលថ្មី មេត្តាឈ្វេងយល់ និងខិតខំអនុវត្តតាមព្រះរាជក្រឹត្យ ដែលកំណត់ពីតួនាទីភារកិច្ច និងលិខិតបទដ្ឋានគតិយុត្តនានា ខណៈវិសាលភាពកាន់តែធំ ដែលគ្របដណ្តប់លើវិស័យសាធារណៈថែមទៀត ដើម្បីបំពេញនិរន្តរភាពរបស់ខ្លួនឲ្យកាន់តែមានលក្ខណៈល្អប្រសើរជាងមុន។

**ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានថ្លែងឲ្យដឹងថា៖ ប.ស.ស. ត្រូវបានបង្កើតឡើងដំបូងដោយអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ មានឈ្មោះថា បេឡាជាតិរបបសន្តិសុខសង្គម ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ៩រូប ហើយកន្លងទៅថ្មីៗនេះ អង្គភាពនេះត្រូវបានប្តូរឈ្មោះទៅជា បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ១១រូប ជាមួយនឹងច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី





បានអនុម័តឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រប់គ្រងផ្នែកចំនួន ៤ រួមមាន៖

- ផ្នែកប្រាក់សោធន
- ផ្នែកថែទាំសុខភាព
- ផ្នែកហានិភ័យការងារ
- ផ្នែកនិកម្មភាពការងារ

វិសាលភាពលើបុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើក្នុងផ្ទះព្រមទាំងបុគ្គលស្វ័យនិយោជន៍។

**ឯកឧត្តមអគ្គនាយក** បានបញ្ជាក់ទៀតថា៖ បច្ចុប្បន្ន ប.ស.ស. បាននឹងកំពុងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គម ចំនួន ២ផ្នែក គឺផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលមានសមាជិកសរុបប្រមាណជាង ២លាននាក់ ដែលពួកគាត់មានសិទ្ធិក្នុងការទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. រួមទាំងអត្ថប្រយោជន៍របបសន្តិសុខសង្គមផ្សេងៗជាច្រើនទៀតផងដែរ។

សូមបញ្ជាក់ថា៖ ពិធីប្រកាសសមាសភាពក្រុមប្រឹក្សាភិបាល ប.ស.ស. អាណត្តិទី១ ខាងលើត្រូវបានរៀបចំឡើងនៅសាលប្រជុំធំនៃទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ដោយមានវត្តមានចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលអាណត្តិទី១ រួមទាំងថ្នាក់ដឹកនាំនៃបេឡាជាតិសន្តិសុខសង្គមសរុបប្រមាណជាង ៦០រូប៕









# ក្រុមប្រឹក្សាភិបាល ប.ស.ស. រៀបចំកិច្ចប្រជុំលើកទី១ របស់ខ្លួនទៅតាមកម្មវិធីដែលបានគ្រោងទុក

នៅថ្ងៃចន្ទ ទី៣១ ខែសីហា ឆ្នាំ២០២០ នេះ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំលើកទី១ តាមកម្មវិធីដែលបានគ្រោងទុកបន្ទាប់ពីបានប្រកាសសមាសភាពក្រុមប្រឹក្សាភិបាល ប.ស.ស. អាណត្តិទី១ កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ កន្លងមកនេះ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. លើកទី១នេះ មានរបៀបវារៈដូចខាងក្រោម៖

១.ត្រួតពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃបេឡាជាតិសន្តិសុខសង្គម និងបទបញ្ជាផ្ទៃក្នុងរបស់បេឡាជាតិសន្តិសុខសង្គម

២.សេចក្តីព្រាងសេចក្តីសម្រេចស្តីពីបែបបទ និងនីតិវិធី នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

៣.ផ្សេងៗ។









គួររំលឹកថា ប.ស.ស. ត្រូវបានបង្កើតឡើងដំបូងដោយអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ មានឈ្មោះថា បេឡាជាតិរបបសន្តិសុខសង្គម ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ៩រូប ហើយកន្លងទៅថ្មីៗនេះ អង្គភាពនេះត្រូវបានបានប្តូរឈ្មោះទៅជា បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ១១រូប ជាមួយនឹងច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីបានអនុម័តឲ្យប្រើប្រាស់ ដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រប់គ្រងលើផ្នែកចំនួន៤ រួមមាន៖

- ផ្នែកប្រាក់សោធន
- ផ្នែកថែទាំសុខភាព
- ផ្នែកហានិភ័យការងារ និង
- ផ្នែកនិកម្មភាពការងារ

មានវិសាលភាពគ្របដណ្តប់លើបុគ្គល ដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើក្នុងផ្ទះព្រមទាំងបុគ្គលស្វ័យនិយោជន៍។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំក្រុមប្រឹក្សាភិបាលនៃទីស្នាក់ការកណ្តាលបេឡាជាតិសន្តិ-សុខសង្គម រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលចំនួន ១១រូប៕










# ក្រុមប្រឹក្សាភិបាល ប.ស.ស. បន្តកិច្ចប្រជុំពិភាក្សាលើកទី២ អាណត្តិទី១ របស់ខ្លួន តាមកម្មវិធីដែលបានគ្រោងទុក

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំពិភាក្សាលើកទី២ អាណត្តិទី១ នាថ្ងៃអង្គារ ទី៦ ខែតុលា ឆ្នាំ២០២០ នេះ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. លើកទី២ នេះដែរ គឺផ្តោតសំខាន់ទៅលើរបៀបវារៈដូចខាងក្រោម៖

(១) ត្រួតពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ

(២) សេចក្តីព្រាងសេចក្តីសម្រេចស្តីពីលក្ខន្តិកៈបុគ្គលិក នៃបេឡាជាតិសន្តិសុខសង្គម

(៣) បញ្ហាផ្សេងៗ។





ថ្លែងទៅកាន់អង្គប្រជុំ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានធ្វើការកោតសរសើរ និងអរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ទាំងអស់ ដែលបានអញ្ជើញចូលរួម និងខិតខំយកចិត្តទុកដាក់ពិភាក្សារៀបចំនូវសេចក្តីព្រាងឯកសារទាំងនេះឡើងដើម្បីដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាភិបាលពិនិត្យពិភាក្សា និងអនុម័ត។

ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ក៏បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវបន្តសិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានបន្ថែមទៀត ឲ្យបានគ្រប់ជ្រុងជ្រោយ ស្របទៅតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម និងរៀបចំយន្តការអនុវត្តតាមគោលការណ៍នានារបស់រាជរដ្ឋាភិបាល សំដៅធានាបាននូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ប្រកបដោយចីរភាព។

ទាំងអស់នេះគឺដោយសារមានការយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តែងតែគិតគូរ និងខ្វល់ខ្វាយ ពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សា និងអនុម័តខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំក្រុមប្រឹក្សាភិបាល នៃទីស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាល ចំនួន ១១រូប៕










# ក្រុមប្រឹក្សាភិបាល ប.ស.ស. បានបើកកិច្ចប្រជុំពិភាក្សាលើចំណុចដែលនៅសល់ពីកិច្ចប្រជុំលើកទី២ អាណត្តិទី១ របស់ខ្លួនបន្តទៀតតាមកម្មវិធីដែលបានគ្រោងទុក

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងការដឹកនាំកិច្ចប្រជុំពិភាក្សាលើកទី៣ អាណត្តិទី១ ទាក់ទងទៅនឹងរបៀបវារៈដែលនៅសេសសល់នាថ្ងៃអង្គារ ទី១៣ ខែតុលា ឆ្នាំ២០២០។

សូមបញ្ជាក់ថាកាលពីថ្ងៃអង្គារ ទី៦ ខែតុលា សប្តាហ៍កន្លងទៅ មានរបៀបវារៈចំនួន២ត្រូវបានក្រុមប្រឹក្សាភិបាលលើកយកមកពិភាក្សា និងអនុម័តរួចហើយ ក្នុងនោះមាន៖

(១) ត្រួតពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ។ ដោយឡែកសម្រាប់របៀបវារៈទី២ស្តីពីសេចក្តីព្រាងសេចក្តីសម្រេចស្តីពីលក្ខន្តិកៈបុគ្គលិក នៃបេឡាជាតិសន្តិសុខសង្គម និងទី៣ បញ្ហាផ្សេងៗត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំលើកទី៣ នេះវិញ។







ថ្លែងទៅកាន់អង្គពិភាក្សា **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានអរគុណដល់សមាជិកក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. ទាំងអស់ ដែលបានខិតខំយកចិត្តទុកដាក់ និងអនុវត្តតួនាទីរបស់ខ្លួនបានយ៉ាងល្អទៅតាមអ្វីដែលអង្គពិភាក្សាបានដាក់ចេញកាលពីសប្តាហ៍កន្លងទៅ។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវបន្តពិភាក្សាឲ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀតដើម្បីឲ្យកាន់តែមានលក្ខណៈល្អឡើង ធ្វើយ៉ាងណាឲ្យការអនុវត្តតាមគោលការណ៍នានារបស់រាជរដ្ឋាភិបាល ធានាបាននូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ប្រកបដោយចីរភាព។

គួររំលឹកថា ជារៀងរហូតមកប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តែងតែគិតគូរ និងខ្វល់ខ្វាយបំផុតពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិតនេះតែម្តង។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សាខាងលើប្រព្រឹត្តទៅពេញមួយព្រឹកនៅសាលប្រជុំក្រុមប្រឹក្សាភិបាលនៃទីស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលចំនួន ១០រូប៕








# ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បានបន្តបើកកិច្ចប្រជុំពិភាក្សា និងអនុម័ត លើរបៀបវារៈដែលបានគ្រោងទុក

កិច្ចប្រជុំពិភាក្សានៅថ្ងៃចន្ទ ទី២៨ ខែធ្នូ ឆ្នាំ២០២០នេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ក្នុងការដឹកនាំកិច្ចប្រជុំលើកទី៤ អាណត្តិទី១ ដើម្បីពិភាក្សា និងអនុម័ត លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន និងបញ្ហាផ្សេង។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានស្នើដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវបន្តពិភាក្សាឲ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត ដើម្បីឲ្យច្បាប់បានអនុម័ត រួចហើយកាន់តែមានលក្ខណៈល្អឡើង ធ្វើយ៉ាងណាឲ្យការអនុវត្តតាមគោលការណ៍នានារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការធានាបាននូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត ប្រកបដោយចីរភាព។





គួររំលឹកថា កន្លងមក ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បានបើកកិច្ចប្រជុំពិភាក្សារបស់ខ្លួនចំនួន ៣លើករួចមកហើយ ដែលក្នុងនោះ បានសម្រេច និងអនុម័តទៅលើ៖

- អនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបេឡាជាតិសន្តិសុខសង្គម
- បទបញ្ជាផ្ទៃក្នុងរបស់បេឡាជាតិសន្តិសុខសង្គម
- សេចក្តីសម្រេចស្តីពីបែបបទ និងនីតិវិធី នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម
- អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ
- សេចក្តីសម្រេចស្តីពីលក្ខន្តិកៈបុគ្គលិក នៃបេឡាជាតិសន្តិសុខសង្គម

សូមបញ្ជាក់ថា៖ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅពេញមួយព្រឹកនៅសាលប្រជុំក្រុមប្រឹក្សាភិបាលនៃទីស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាល ចំនួន ១០រូប។











# កម្មវិធីទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រតាមប្រព័ន្ធទូរស័ព្ទដៃ (NSSF Claim Mobile App) ត្រូវបានលើកយកមកប្រជុំពិភាក្សាបន្ត

កម្មវិធីទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រតាមប្រព័ន្ធទូរស័ព្ទដៃ (NSSF Claim Mobile App) ដែលត្រូវបានលើកយកមកប្រជុំពិភាក្សាបន្តនាថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ នៅសាលប្រជុំស្នាក់ការកណ្តាលនៃ ប.ស.ស. ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ថ្លែងក្នុងកិច្ចប្រជុំពិភាក្សានេះ **ឯកឧត្តមអគ្គនាយក** បានបញ្ជាក់ថាកន្លងមកបេឡាជាតិសន្តិសុខសង្គម បានអនុវត្តយន្តការនៃការទូទាត់សេវា ដែលតម្រូវឲ្យមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ស្នើសុំទូទាត់ថ្លៃសេវាដោយភ្ជាប់មកជាមួយនូវលិខិតប្រើប្រាស់សេវារបស់សមាជិក (Patient Form), វិក្កយបត្រ, វេជ្ជបញ្ជា។ល។ មកបេឡាជាតិសន្តិសុខសង្គម ដើម្បីសម្រួលដល់យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រនេះ ឲ្យកាន់តែមានភាពងាយស្រួល និងមានសុក្រឹតភាពទៅលើការពិនិត្យសុពលភាព ជាពិសេសសុក្រឹតភាពក្នុងការទូទាត់ ព្រមទាំងកាត់បន្ថយការប្រើប្រាស់ឯកសារជាក្រដាស និងចំណេញពេលវេលាក្នុងការងាររដ្ឋបាល បេឡាជាតិសន្តិសុខសង្គម បានសម្រេច រៀបចំកម្មវិធីទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រតាមប្រព័ន្ធទូរស័ព្ទដៃ (NSSF Claim Mobile App) ដែលនឹងត្រូវចាប់ផ្តើមដាក់ឲ្យដំណើរការនាពេលខាងមុខ។

សូមបញ្ជាក់ថា កិច្ចប្រជុំខាងលើប្រព្រឹត្តទៅដោយមានការចូលរួមពីលោក Hubert Zander ទីប្រឹក្សាបច្ចេកទេសនៃ ប.ស.ស. លោក Kelvin Hui HSF Component Leader Social Health Protection នៃអង្គការ GIZ និងលោក Song Chhiay ទីប្រឹក្សាផ្នែកកិច្ចគាំពារសង្គម៕







# បេឡាជាតិសន្តិសុខសង្គម រៀបចំ កិច្ចប្រជុំប្រចាំខែដំបូងរបស់ខ្លួនតាមប្រព័ន្ធវីដេអូ (Video Conference)

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំប្រចាំខែ ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិសុខសង្គម ដែលមានការចូលរួមលោក លោកស្រីជាប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. តាមបណ្តាសាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌ តាមប្រព័ន្ធវីដេអូ (Video Conference)។

**ឯកឧត្តមអគ្គនាយក** បានថ្លែងការកោតសរសើរចំពោះថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី និងបុគ្គលិក បេឡាជាតិសន្តិសុខសង្គម ដែលកន្លងមកនេះ បានអនុវត្ត និងបំពេញការងាររបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរគួរឲ្យកត់សម្គាល់ ទន្ទឹមគ្នានឹងស្ថានភាពនៃការឆ្លងនៃវីរុស COVID-19 នៅតែអូសបន្លាយ ដែលបង្កឲ្យមានផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចពិភពលោកយ៉ាងធ្ងន់ធ្ងរ ក្នុងនោះប្រទេសកម្ពុជាយើងក៏បានរងផលប៉ះពាល់ផងដែរ ។

ជាមួយគ្នានោះ **ឯកឧត្តមអគ្គនាយក** បានថ្លែងបន្តថា៖ បងប្អូនប្រជាពលរដ្ឋទាំងអស់ ពិសេសបងប្អូនកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្ពស់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាបាននិរន្តរភាពការងារក្នុងសម័យ COVID-19 ដែលបានដាក់





ចេញនូវផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុសារធារណៈចំនួន ៤ចំណុច រួមមាន ៖

ទី១៖ ការប្រយុទ្ធប្រឆាំងជំងឺ COVID-19

ទី២៖ ការរក្សាលំនឹងជីវភាពប្រជាជនក្នុងកម្រិតអប្បបរមា

ទី៣៖ ការខិតខំជួយឲ្យអស់លទ្ធភាពដើម្បីបន្តនិរន្តរភាពអាជីវកម្ម និង

ទី៤៖ រក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ។

**ឯកឧត្តមអគ្គនាយក** បានជំរុញបន្ថែមទៅដល់លោក លោកស្រី ដែលជាប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. គ្រប់ការិយាល័យ និងគ្រប់សាខាទាំងអស់ធ្វើយ៉ាងណាពន្លឿនក្នុងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ ពិសេសគឺប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីសម្រាលកូនឲ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងផ្តល់ការសម្របសម្រួលឲ្យបានទាន់ពេលវេលា ចំពោះបងប្អូនដែលជាសមាជិកទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូ ប.ស.ស.។ ម្យ៉ាងទៀតគ្រប់ការិយាល័យ ប.ស.ស. ទាំងអស់ត្រូវបន្តចូលរួមទប់ស្កាត់នៃការឆ្លងនៃវីរុស COVID-19 នេះទៅតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាល។

សូមបញ្ជាក់ថា កិច្ចប្រជុំប្រចាំខែតាមប្រព័ន្ធវីដេអូ (Video Conference) ខាងលើ ត្រូវបានប្រព្រឹត្តទៅ នាព្រឹកថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ នៅសាលប្រជុំស្នាក់ការកណ្តាលនៃ ប.ស.ស.ក្នុងរាជធានីភ្នំពេញ តាមរយៈវីដេអូ Conference៕











# អគ្គនាយក ប.ស.ស. ទទួលជួបពិភាក្សាការងារ ជាមួយដៃគូអភិវឌ្ឍន៍

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. និងថ្នាក់ដឹកនាំ ប.ស.ស. ជួបពិភាក្សាការងារ ជាមួយដៃគូអភិវឌ្ឍន៍ (Development Partners) រួមមាន តំណាងអង្គការអន្តរជាតិខាងការងារ (ILO) តំណាងកម្មវិធីរោងចក្រកាន់តែប្រសើរកម្ពុជា (BFC) តំណាងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) តំណាងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) តំណាងអង្គការហ្គ្រេត (GRET) តំណាងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) នៅថ្ងៃសុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ នៅសាលប្រជុំទីស្នាក់ការកណ្តាល ប.ស.ស.។





ក្នុងកិច្ចជំនួបពិភាក្សាខាងលើមានគោលបំណងផ្តោតសំខាន់ៗទៅលើ៖

- ការពិភាក្សា និងការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពនៃការបង្កើត និងរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃ ប.ស.ស.

- ការពិភាក្សាលើការត្រួតពិនិត្យឡើងវិញនៃធានារ៉ាប់រងសុខភាពជាតិ

- ការពិភាក្សាលើគម្រោងទំនើបភាវូបនីយកម្ម ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាថ្មី ដើម្បីគាំទ្រដំណើរការរបស់ ប.ស.ស.

- ការពិភាក្សា និងការធ្វើបច្ចុប្បន្នភាពលើការផ្តល់មូលនិធិរបស់ក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៃប្រទេសអាល្លឺម៉ង់ដល់ ប.ស.ស. សម្រាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ

- ការពិភាក្សា និងចែករំលែក ស្តីពីផ្នែកគាំទ្រនាពេលអនាគតមក ប.ស.ស. ដែលត្រូវបានផ្តល់ដោយអង្គការ ILO និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។

សូមបញ្ជាក់ថា កន្លងមក ប.ស.ស. បានទទួលការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍន៍ ដែលនេះសបញ្ជាក់ពីការចូលរួមក្នុងការបន្តការសហការ ដើម្បីអភិវឌ្ឍន៍នូវការអនុវត្តប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព៕















# អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ នៅតែបន្តកិច្ចសហការ ជួយគាំទ្រដល់បេឡាជាតិសន្តិសុខសង្គមនៅកម្ពុជា

តំណាងអង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិនៅតែបន្តកិច្ចសហការក្នុងការជួយគាំទ្រដល់បេឡាជាតិសន្តិសុខសង្គមនៅកម្ពុជា ត្រូវបានលើកឡើងនៅក្នុងជំនួបពិភាក្សាមួយរវាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៅសាលប្រជុំក្រុមប្រឹក្សាភិបាល ប.ស.ស. រាជធានីភ្នំពេញ នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០។

ក្នុងជំនួបពិភាក្សានេះដែរ **ឯកឧត្តមអគ្គនាយក** បានស្នើដល់ដៃគូអភិវឌ្ឍន៍ (Development Partners) មកពីអង្គការអន្តរជាតិខាងការងារ (ILO) និងប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា (EU Delegation) បន្តជួយគាំទ្របន្ថែមទៀតលើការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាផ្នែកបច្ចេកទេសមួយចំនួន ធ្វើយ៉ាងណាឲ្យការផ្តល់សេវាសន្តិសុខសង្គមនៅកម្ពុជាកាន់តែទទួលបាននូវគុណភាព និងទាន់ពេលវេលា។







នាឱកាសនោះ ភាគីទាំងពីរក៏បានធ្វើការវាយតម្លៃខ្ពស់ចំពោះកិច្ចសហការរវាងបេឡាជាតិសន្តិសុខសង្គមកម្ពុជាជាមួយដៃគូអភិវឌ្ឍន៍ (Development Partners) មកពីអង្គការអន្តរជាតិខាងការងារ (ILO) និងប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា (EU Delegation) ហើយភាគីទាំងពីរនៅតែបន្តកិច្ចសហការដ៏ល្អដើម្បីឲ្យការងារមួយនេះកាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

តំណាងអង្គការអន្តរជាតិខាងការងារ (ILO) លោក Finn Koh ក៏បានធ្វើការកោតសរសើរចំពោះការផ្តល់សេវាសន្តិសុខសង្គមនៅកម្ពុជា ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសមាជិករបស់ខ្លួន។ កន្លងមក ប.ស.ស.បានទទួលការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍អន្តរជាតិជាច្រើនផងដែរ នេះសបញ្ជាក់ពីការចូលរួមក្នុងការបន្តការសហការដើម្បីអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

សូមបញ្ជាក់ថាកិច្ចជំនួបពិភាក្សាការងារខាងលើ ប្រព្រឹត្តទៅដោយមានការចូលរួមពីអង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ (Development Partners) មកពីអង្គការអន្តរជាតិខាងការងារ (ILO) និងប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា (EU Delegation )៕













# ប.ស.ស. រៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទង និងរបបសន្តិសុខសង្គម តាមប្រព័ន្ធវីដេអូ (Video Conference)

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខណៈជាអធិបតីភាពក្នុងកិច្ចប្រជុំប្រចាំខែ ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិ-សុខសង្គម ដល់លោក លោកស្រីជាប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. តាមបណ្តាសាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌ តាមប្រព័ន្ធវីដេអូ ( Video Conference) បានថ្លែងការកោតសរសើរចំពោះថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី និងបុគ្គលិក បេឡាជាតិសន្តិសុខសង្គម ដែលកន្លងមកនេះ បានអនុវត្ត និងបំពេញការងាររបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរគួរឲ្យកត់សម្គាល់។

ទន្ទឹមគ្នានេះ **ឯកឧត្តមអគ្គនាយក** បានមានប្រសាសន៍អំពីស្ថានភាពបច្ចុប្បន្ននៃប្រទេសកម្ពុជា ដែលកំពុងជួបប្រទះនូវបញ្ហាគ្រោះធម្មជាតិទឹកជំនន់ដោយសារទឹកភ្លៀង តាមបណ្តាខេត្តមួយចំនួនកំពុងទទួលរងផលប៉ះពាល់។ ដូចនេះ **ឯកឧត្តមអគ្គនាយក** ស្នើសុំឲ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកតាមបណ្តាសាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌ នីមួយៗ ជាពិសេសខេត្តដែលទទួលរងគ្រោះទឹកជំនន់ ត្រូវធ្វើយ៉ាងណាធានាសុវត្ថិ-ភាពរបស់ខ្លួន និងបន្តអនុវត្តការងារឲ្យល្អប្រសើរជូនដល់បងប្អូនកម្មករនិយោជិត ដែលជាសមាជិក ប.ស.ស.។









ជាមួយគ្នានេះ ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាក៏សូមឲ្យប្រជាពលរដ្ឋ រក្សាសុវត្ថិភាពផ្ទាល់ខ្លួន ក្រុមគ្រួសារ ជាពិសេសប្រជាពលរដ្ឋដែលស្ថិតនៅតំបន់ដែលកំពុងរងគ្រោះដោយទឹកជំនន់ ត្រូវជម្លៀសរកទីទួលសុវត្ថិភាព។ ជាការពិតណាស់ **សម្តេច** តែងតែគិតគូរ និងខ្វល់ខ្វាយបំផុត ពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត។

ក្នុងឱកាសនេះដែរ **ឯកឧត្តមអគ្គនាយក** បានជំរុញបន្ថែមទៅដល់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. គ្រប់ការិយាល័យ និងគ្រប់សាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌទាំងអស់ធ្វើយ៉ាងណា ពន្លឿនក្នុងការផ្តល់សេវាដល់សមាជិក ប.ស.ស. ឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងផ្តល់ការសម្របសម្រួលឲ្យទាន់ពេលវេលាចំពោះបងប្អូនដែលជាសមាជិកពេលទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូ ប.ស.ស.។

សូមបញ្ជាក់ថា កិច្ចប្រជុំ ខាងលើ ត្រូវបានប្រព្រឹត្តទៅនៅថ្ងៃពុធ ១២រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០៕









# វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន តាមរយៈវីដេអូ (Video Conference)

ការបើកវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន តាមរយៈវីដេអូ (Video Conference) នេះដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់ លោក លោកស្រីជាប្រធានការិយាល័យ ប.ស.ស. សាខាខេត្ត-ខណ្ឌទាំងអស់ ដែលអញ្ជើញប្រកាសបើកវគ្គក្រោមអធិបតីភាព **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នាថ្ងៃព្រហស្បតិ៍ ទី១២ ខែវិច្ឆិកា ឆ្នាំ២០-២០ នៅសាលប្រជុំស្នាក់ការកណ្តាលនៃ ប.ស.ស. រាជធានីភ្នំពេញ ។

**ឯកឧត្តមអគ្គនាយក** ក្នុងឱកាសអញ្ជើញបើកវគ្គបណ្តុះបណ្តាលខាងលើ បានថ្លែងកោតសរសើរចំពោះថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី និងបុគ្គលិក បេឡាជាតិសន្តិ-សុខសង្គម ដែលបានអនុវត្ត និងបំពេញការងាររបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរគួរឲ្យកត់សម្គាល់នាពេលកន្លងមក។

ជាមួយគ្នានេះផងដែរ **ឯកឧត្តមអគ្គនាយក** បានជំរុញ និងលើកទឹកចិត្តទៅដល់លោក លោកស្រីដែលជាប្រធាន អនុប្រធាន គ្រប់សាខា ប.ស.ស. ខេត្ត ខណ្ឌទាំងអស់ ត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងវគ្គបណ្តុះបណ្តាលនេះ ក្នុងន័យ បង្កើនបន្ថែមទៀតនូវចំណេះដឹងថ្មីៗ ព្រមទាំងស្មារតីទទួលខុសត្រូវប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់សេវារបបសន្តិសុខសង្គម ជូនបងប្អូនដែលជាសមាជិករបស់ខ្លួន។







ទន្ទឹមគ្នានឹងស្ថានភាពនៃការឆ្លងវីរុសកូវីដ-១៩ នៅតែបន្តអូសបន្លាយ ដែលបង្កឲ្យមានផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចពិភពលោក យ៉ាងធ្ងន់ធ្ងរ រួមទាំងប្រទេសកម្ពុជាយើងផងដែលនោះ **ឯកឧត្តមអគ្គនាយក** បានក្រើនរំលឹកដល់ លោក លោកស្រីដែលជាប្រធាន អនុប្រធាន គ្រប់សាខា ប.ស.ស. ខេត្ត ខណ្ឌទាំងអស់ធ្វើយ៉ាងណារួមគ្នាចូលរួមទប់ស្កាត់នៃការរីករាលដាលនៃការឆ្លងវីរុសកូវីដ-១៩ នេះ ឆ្លើយតបទៅនឹងការអំពាវនាវពីសំណាក់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែគិតគូរ និងយកចិត្តទុកដាក់ខ្ពស់បំផុតអំពីសុខទុក្ខ សុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ គ្រប់ពេលវេលា៕











# វគ្គបណ្តុះបណ្តាលស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" ជូនដល់ មន្ត្រី បុគ្គលិកជំនាញ គ្រប់ការិយាល័យ នៃស្នាក់ការ ប.ស.ស.

វគ្គបណ្តុះបណ្តាល "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" របស់បេឡាជាតិសន្តិសុខសង្គម ជូនដល់ មន្ត្រី បុគ្គលិកជំនាញ គ្រប់ការិយាល័យ នៃស្នាក់ការកណ្តាល ប.ស.ស. ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម បន្ទាប់ពី **ឯកឧត្តមអគ្គនាយក** បើកវគ្គបណ្តុះបណ្តាលតាមរយៈវីដេអូ Conference ទៅដល់មន្ត្រីគ្រប់សាខា ប.ស.ស. ខេត្ត-ខណ្ឌ ម្តងរួចមកហើយ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២០ កន្លងមកថ្មីៗនេះ។

**ឯកឧត្តមអគ្គនាយក** បានបញ្ជាក់ថា៖ចំពោះរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា បង្កើតឡើងក្នុងគោលដៅធានាឲ្យមានសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលទាក់ទងទៅនឹងតាវកាលិកផ្នែកប្រាក់សោធន រួមមានសោធនជរាភាព សោធនទុព្វលភាព និងសោធនឧត្តរជីវី។










របបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះ ជាសមិទ្ធផលថ្មីក្នុងសម័យសន្តិភាព ដូចនេះ មន្ត្រី បុគ្គលិកជំនាញគ្រប់ការិយាល័យទាំងអស់ នៃ ប.ស.ស. ត្រូវយកចិត្តទុកដាក់ខិតខំរៀនសូត្រ និងយល់ដឹងឲ្យបានច្បាស់ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន និងដើម្បីជាមធ្យោបាយក្នុងការផ្សព្វផ្សាយទៅកាន់សមាជិក ក៏ដូចជាសហគ្រាស គ្រឹះស្ថាន និងអង្គភាពពាក់ព័ន្ធទាំងអស់ឲ្យយល់ដឹងពីអត្ថប្រយោជន៍ដែលពួកគាត់ត្រូវទទួលបាន។

**ឯកឧត្តមអគ្គនាយក** បានថ្លែងបន្តថា៖ ដោយមានការយកចិត្តទុកដាក់គិតគូរពីសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា របបសន្តិសុខសង្គមផ្នែកប្រាក់សោធន នឹងដាក់ដំណើរការ នាពេលឆាប់ៗខាងមុខនេះ ហើយបុគ្គលដែលត្រូវគាំពារផ្នែកប្រាក់សោធនមានដូចជា៖ បុគ្គលដែលស្ថិតនៅក្នុងវិស័យ



សាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ផងដែរ។

**ឯកឧត្តមអគ្គនាយក** នៅតែបន្ត ក្រើនរំលឹកដល់ លោក លោកស្រីដែលជាមន្ត្រី បុគ្គលិក នៃ ប.ស.ស. ទាំងអស់ធ្វើយ៉ាងណារួមគ្នាទប់ស្កាត់នៃការរីករាលដាលនៃការឆ្លងវីរុសកូវីដ-១៩ នេះ ឆ្លើយតបទៅនឹងការអំពាវនាវពីសំណាក់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា តាមរយៈវិធានការរបស់ក្រសួងសុខាភិបាល។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" នេះ មានរយៈពេលមួយថ្ងៃ ប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមានការចូលរួមពីមន្ត្រី បុគ្គលិក ប្រមាណជាង១៦០នាក់ នៅសាលប្រជុំធំ នៃ ប.ស.ស. ស្នាក់ការរាជធានីភ្នំពេញ៕






# បេឡាជាតិសន្តិសុខសង្គមកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) លើកទី៣៧ តាមរយៈប្រព័ន្ធវីដេអូ ក្នុងខណៈពេលដែលកូវីដ-១៩ នៅតែបន្តផ្ទុះឡើងក្នុងបណ្តាប្រទេសមួយចំនួន លើសកលលោក

ក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន [ASEAN Social Security Association (ASSA)] នៅថ្ងៃពុធ ទី៩ ខែធ្នូ ឆ្នាំ២០២០ នេះបានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣៧ ក្រោមប្រធានបទស្តីពី "ការពង្រីកការគ្របដណ្តប់របបសន្តិសុខសង្គម" ។

នេះគឺជាលើកទី១ ដែល ប.ស.ស. កម្ពុជា បានរៀបចំជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៧ នេះឡើងតាមរយៈប្រព័ន្ធវីដេអូ (Video Conference) ដោយមានការចូលរួមពីតំណាងប្រធានសន្តិសុខសង្គមអាស៊ានទាំង ១០ប្រទេស សរុបចំនួន ២១ស្ថាប័ន ដែលប្រព្រឹត្តទៅនៅសាលប្រជុំធំនៃ ប.ស.ស. រាជធានីភ្នំពេញ ។

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ជាប្រធាននៃកិច្ចប្រជុំដ៏សំខាន់មួយនេះ ក្រោមការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម។ **ឯកឧត្តមអគ្គនាយក** បានថ្លែងថា៖ រាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់








ខ្ញុំសូមសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី គណៈប្រតិភូ នៃបណ្តាប្រទេសអាស៊ាន ដែលបានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASEAN Social Security Association, ASSA) លើកទី៣៧ តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមអគ្គនាយក** ថ្លែងបន្តថា ក្នុងរយៈពេលជាង ៥៣ឆ្នាំកន្លងមកនេះ អាស៊ានសម្រេចបានសមិទ្ធផលចម្បងជាច្រើន ជាពិសេសសមិទ្ធផលថ្មីៗ ក្នុងការកសាងសហគមន៍អាស៊ានទៅតាមសរសរស្តម្ភទាំងបី គឺសហគមន៍នយោបាយសន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន។ ទន្ទឹមនឹងនេះ យើងក៏បានមើលឃើញអំពីបញ្ហាប្រឈម និងកិច្ចការជាច្រើននៅចំពោះមុខ ដែលតម្រូវឲ្យមានការរួបរួមគ្នា ពុះពារជម្នះ និងដោះស្រាយ ក្នុងស្ថានភាពដែលមានការវិវត្តប្រែប្រួលយ៉ាងឆាប់រហ័ស នៅក្នុងសភាពការណ៍នយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម ទាំងក្នុងកម្រិតសកល និងទាំងក្នុងកម្រិតតំបន់។









ប្រការនេះតម្រូវឲ្យយើងទាំងអស់គ្នាបង្កើនការខិតខំទ្វេដងបន្ថែមទៀតនៅក្នុងសម័យកាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលនៅតែបន្តឆ្លងក្នុងតំបន់ និងជាសកល ដែលជាកត្តានាំឲ្យយើងត្រូវខិតខំរួបរួមគ្នា ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការចែករំលែកផ្លែផ្កា នៃកំណើននេះ ឲ្យបានកាន់តែប្រសើរឡើងក្នុងបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ ជាពិសេសលើផ្នែករបបសន្តិសុខសង្គម ។ ក្នុងឱកាសនោះ**ឯកឧត្តម** បានវាយតម្លៃខ្ពស់ចំពោះអង្គភាពសន្តិសុខសង្គម ជាសមាជិកនៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ទាំងអស់ និងអង្គការជាតិ-អន្តរជាតិ ដែលបានគាំទ្រ និងផ្តល់នូវកិច្ចសហការកន្លងមកលើវិស័យសន្តិសុខសង្គម ក៏ដូចជាទៅអនាគត ក្នុងការចូលរួមចំណែកចែករំលែកចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមកសម្រាប់ការអភិវឌ្ឍប្រទេសក្រោមបាវចនា "ចក្ខុវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ (One vision, One Identity, One Community)" ។

**ឯកឧត្តម** បានបន្តថា ចាប់តាំងពីបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលជាសមាជិក នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) កាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ រហូតមកដល់ពេលបច្ចុប្បន្ននេះ ប.ស.ស. ទទួលបាននូវបទពិសោធន៍ និងចំណេះដឹងជាច្រើនខាងវិស័យសន្តិសុខសង្គម ព្រមទាំងមានការកោតសរសើរពីស្ថាប័នជាតិ និងអន្តរជាតិ ក្នុងការលើកកម្ពស់ឧត្តមភាព នៃការគ្រប់គ្រងចាត់ចែងប្រព័ន្ធសន្តិសុខសង្គម និងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមប្រកបដោយថាមវន្ត។

**ឯកឧត្តមអគ្គនាយក** បានបន្តថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលមានលក្ខណៈ ទូលំទូលាយ ផ្តោតលើសសរស្តម្ភចំនួនពីរ គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ដែលក្របខណ្ឌគោលនយោបាយមួយនេះ ដើរតួយ៉ាងសំខាន់ក្នុងការបង្កើនលទ្ធភាពទទួលសេវាជំនួយសង្គម និងសន្តិសុខសង្គម សម្រាប់មន្ត្រីសាធារណៈ និងវិស័យឯកជន ព្រមទាំងប្រជាជន នៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់យ៉ាងខ្ពស់របស់រាជរដ្ឋាភិបាល ទៅលើការគាំពារសន្តិសុខប្រាក់ចំណូលរបស់ប្រជាពលរដ្ឋគ្រប់រូប និងជាពិសេស គឺការផ្តោតការយកចិត្តទុកដាក់ជាចម្បង លើការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ និងបានផ្តោតសំខាន់ទៅលើការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្រីក្រ ជាពិសេសស្ត្រីមានផ្ទៃពោះជាអាទិភាព ក្នុងនោះ ប.ស.ស. គឺជាប្រតិបត្តិករតែមួយគត់ក្នុងការអនុវត្តទៅលើប្រព័ន្ធសន្តិសុខសង្គម។










ទន្ទឹមគ្នានេះ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា បានសម្រេចការងារសំខាន់ៗ ស្របតាមផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនោះ យុទ្ធសាស្រ្តជាអាទិភាពទី៤ "ការអភិវឌ្ឍរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" ដែលរួមមានការពង្រឹង និងពង្រីកការអនុវត្តផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងត្រៀមដាក់ឲ្យដំណើរការផ្នែកប្រាក់សោធននាពេលដ៏ខ្លីខាងមុខនេះ ព្រមទាំងពង្រីកវិសាលភាពលើរបបសន្តិសុខសង្គមដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាពលរដ្ឋគ្រប់រូប។

**ឯកឧត្តមអគ្គនាយក** បានរំលឹកឲ្យដឹងទៀតថា វិស័យសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ ដែលបច្ចុប្បន្នគ្រប់គ្រងលើផ្នែកចំនួន ៤ រួមមាន៖ ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ ដែលមានវិសាលភាពគ្របដណ្តប់លើបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើ









ក្នុងផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជន៍សំដៅធានាបានប្រសិទ្ធភាពនិរន្តរភាព សង្គតិភាពនៃការអនុវត្តប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ស្របតាមបរិបទនៃបណ្តាប្រទេសក្នុងតំបន់ និងសកលលោកផងដែរ ហើយគិតមកទាល់ពេលនេះបេឡាជាតិសន្តិសុខសង្គមកម្ពុជា មានសមាជិកសរុបប្រមាណជាង ២លាននាក់ហើយ ដែលកំពុងទទួលបានការគាំពារ និងប្រើប្រាស់សេវារបបសន្តិសុខសង្គមមួយនេះ។

តាមរយៈនៃកិច្ចប្រជុំនេះ**ឯកឧត្តម** សំណូមពរដល់សមាជិកទាំងមូល សូមចូលរួមចែករំលែក ផ្តល់នូវបទពិសោធន៍ផ្នែកសន្តិសុខសង្គមពីគ្នាទៅវិញទៅមក ក្នុងនាមជាសមាជិកអង្គភាពសន្តិសុខសង្គម នៃបណ្តាប្រទេសនីមួយៗ ក្នុងការអនុវត្តទទួលបានជោគជ័យកន្លងមក ដើម្បីជាធាតុចូលសម្រាប់ការអភិវឌ្ឍបន្ថែមនូវវិស័យសន្តិសុខសង្គមរបស់ខ្លួន ឲ្យកាន់តែមានការអភិវឌ្ឍបន្ថែមទៀត សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចឲ្យមានការអភិវឌ្ឍកាន់តែច្រើន។




សូមបញ្ជាក់ថា មុនបើកដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) លោក Haji Omar bin Mohd. Dali ប្រធានសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) និងជានាយកនៃអង្គភាព ETF ប្រទេសព្រុយណេដារូសាឡឹម បានថ្លែងតាមរយៈប្រព័ន្ធវីដេអូដែលមានខ្លឹមសារថា នេះគឺជាថ្ងៃប្រវត្តិសាស្ត្រ និងជាលើកទី១ ដែលយើងមិនធ្លាប់ជួបប្រទះពីមុន ដែលបានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) តាមរយៈប្រព័ន្ធវីដេអូ (Video Conference)។ លោកពិតជាសោកស្តាយខ្លាំងណាស់ ដែលមិនបានមកដល់ផ្ទាល់នៃទឹកដីទីក្រុងអង្គរដ៏អច្ឆរិយមួយនេះ។

លោកបានថ្លែងបន្តទៀតថា បើទោះបីជាយ៉ាងណាក៏ដោយ សង្ឃឹមថាកិច្ចប្រជុំ នាថ្ងៃនេះ នឹងជំរុញការទំនាក់ទំនងរវាងប្រទេសជាសមាជិក នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ឲ្យកាន់តែមានភាពជិតស្និទ្ធ និងពង្រឹងចំណងរួមគ្នា ក្នុងការដោះស្រាយរាល់បញ្ហាប្រឈមនានា នៃកិច្ចដំណើរការលើវិស័យសន្តិសុខសង្គម តាមបណ្តាប្រទេសរបស់ខ្លួន៕





# ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃ ប.ស.ស. កម្ពុជាបានចូលរួម វគ្គបណ្តុះបណ្តាល តាមរយៈប្រព័ន្ធវីដេអូ (Video Conference)

ក្រោមការចាត់តាំងពី **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម **ឯកឧត្តម ប៉ែន នរៈវុធ** នាយករង ប.ស.ស. បានដឹកនាំមន្ត្រីបច្ចេកទេស នៃ ប.ស.ស. ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនវានុវត្តន៍របស់រាជរដ្ឋាភិបាល សម្រាប់ការដាក់បញ្ចូលក្រុមជនងាយរងគ្រោះទៅក្នុងសង្គមវិញតាមរយៈប្រព័ន្ធវីដេអូ ( Video Conference) នៅថ្ងៃទី៣ និងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលរៀបចំដោយទីភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់សេដ្ឋកិច្ច និងសង្គមកិច្ច (UNDESA)។





វគ្គបណ្តុះបណ្តាលនេះមានគោលបំណងសំខាន់ផ្តោតលើការកសាងសមត្ថភាពក្នុងការលើកកម្ពស់នវានុវត្តន៍របស់រាជរដ្ឋាភិបាលសម្រាប់ការដាក់បញ្ចូលក្រុមងាយរងគ្រោះទៅក្នុងសង្គមដោយបង្ហាញពីអភិក្រម យុទ្ធសាស្ត្រ និងបទពិសោធន៍ព្រមទាំងជំរុញការដាក់បញ្ចូលក្រុមជនងាយរងគ្រោះទៅក្នុងការរៀបចំគោលនយោបាយ ការអនុវត្ត ការត្រួតពិនិត្យ និងការតាមដានដំណើរការលើក្រុមជនងាយរងគ្រោះដោយផ្ទាល់។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីតំណាងបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម តំណាងរាជរដ្ឋាភិបាល និងតំណាងអង្គការអន្តរជាតិ សរុបប្រមាណ ៥០រូប៕



# សន្និសីទស្តីពី "ការកសាងត្រឡប់មកវិញឲ្យកាន់តែប្រសើរឡើងសម្រាប់ភាពស្អិតរមួត និងការឆ្លើយតបរបស់អាស៊ាន ចំពោះការរីករាលដាលនៃជំងឺរាតត្បាតសកល កូវីដ-១៩"

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ នេះ បានដឹកនាំមន្ត្រីបច្ចេកទេសជំនាញ ចូលរួមសន្និសីទ នៃកិច្ចសន្ទនាត្រីភាគីក្នុងតំបន់អាស៊ានលើកទី១១ (11th ARTSDC) ស្តីពី "ការកសាងត្រឡប់មកវិញឲ្យកាន់តែប្រសើរឡើងសម្រាប់ភាពស្អិតរមួត និងការឆ្លើយតបរបស់អាស៊ាន ចំពោះការរីករាលដាលនៃជំងឺរាតត្បាតសកល COVID-19" ។

សន្និសីទនេះ ធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូ (Video Conference) ក្រោមការរៀបចំឡើងដោយ ក្រសួងការងារ ជនពិការ និងសង្គមកិច្ច ប្រទេសវៀតណាម ក្នុងគោលបំណង ដើម្បីបង្រួបបង្រួមការឆ្លើយតបរបស់ ដៃគូសង្គមលើបញ្ហាដែលកំពុងកើតមានផ្សេងៗគ្នា ក៏ដូចជាពង្រឹងការសន្ទនាសង្គម និងការជំរុញរបៀបវារៈនៃការងារសមរម្យ ដើម្បីគាំទ្រទៅលើទស្សនវិស័យរួមរបស់សហគមន៍អាស៊ានឆ្នាំ២០២៥ និងស្របទៅនឹងសេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលអាស៊ានពិសេសស្តីពី ជំងឺរាតត្បាតសកលកូវីដ-១៩ និងក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន។

សូមបញ្ជាក់ថា៖ សន្និសីទនេះ មានការចូលរួមរវាងត្រីភាគី ដែលមកពីរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកអាស៊ាន តំណាងនិយោជក តំណាងកម្មករនិយោជិត តំណាងដៃគូអភិវឌ្ឍន៍ ក្នុងនោះដែរមានការចូលរួមពីតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជាចំនួន ១១រូប ផងដែរ៕








# កិច្ចប្រជុំពិភាក្សា កម្មវិធី NSSF Member App សម្រាប់សមាជិក ប.ស.ស. ប្រើតាមរយៈទូរស័ព្ទដៃ

នៅថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ នៅសាលប្រជុំស្នាក់ការកណ្តាលនៃ ប.ស.ស. រាជធានីភ្នំពេញ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំនៃកិច្ចប្រជុំពិភាក្សា ជាមួយក្រុមការងារនៃអង្គការ GIZ ស្តីពីវឌ្ឍនភាពនៃកម្មវិធីសំខាន់នេះ។

**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** បានបញ្ជាក់ថាដំណើរការនៃប្រជុំពេញមួយព្រឹកត្រូវបានលើកឡើងនូវបញ្ហាគន្លឹះសំខាន់ៗមួយចំនួនមកពិភាក្សា ក្នុងនោះរួមមាន (១) ដំណើរការនៃកម្មវិធីសម្រាប់សមាជិក ប.ស.ស. តាមរយៈទូរស័ព្ទដៃ (NSSF Member App), (២)ការសិក្សាឈ្វេងយល់ និងរៀបចំឲ្យមានគណៈកម្មការសម្រាប់ការអនុវត្តសាកល្បងកម្មវិធីសម្រាប់សមាជិក ប.ស.ស. តាមរយៈទូរស័ព្ទដៃ (៣) ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការផ្សព្វផ្សាយកម្មវិធីសម្រាប់សមាជិក ប.ស.ស. តាមរយៈទូរស័ព្ទដៃ និង (៤) ដើម្បីសម្រួលដល់បងប្អូនដែលជាសមាជិក ប.ស.ស. ទាំងអស់ឲ្យកាន់តែមានភាពងាយស្រួលក្នុងការឆែកសុពលភាពប័ណ្ណសមាជិក ប.ស.ស. របស់ខ្លួន រួមទាំងព័ត៌មានផ្សេងៗទៀតក៏ដូចជាចំនួនដងនៃការទៅប្រើប្រាស់សេវានៅតាមមន្ទីរសុខាភិបាលផងដែរ។

សូមបញ្ជាក់ថា៖កិច្ចប្រជុំខាងលើប្រព្រឹត្តទៅដោយមានការចូលរួមពីលោក Hubert Zander ទីប្រឹក្សាបច្ចេកទេសនៃ ប.ស.ស. លោក Kelvin Hui HSF Component Leader Social Health Protection នៃអង្គការ GIZ និងលោក Song Chhiay ទីប្រឹក្សាផ្នែកកិច្ចគាំពារសង្គម៕









# មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមឈ្វេងយល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់របបសន្តិសុខសង្គម

ក្រុមការងារ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ សហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីការផ្តល់សេវាកម្ម និងអត្ថប្រយោជន៍នៃការប្រើប្រាស់របបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅសាលសន្និសីទ គ.ជ.ប ជាន់ទី១។

ឆ្លៀតក្នុងឱកាសនោះ **លោក សុក ប៊ូរ៉ា** ប្រធានការិយាល័យតាវកាលិក នៃ ប.ស.ស. បានធ្វើបទបង្ហាញស្តីពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប័ណ្ណសមាជិក ប.ស.ស. និងតាវកាលិកហានិភ័យការងារ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឲ្យពួកគាត់ឈ្វេងយល់ពីផ្នែកហានិភ័យការងារ និងសេវាថែទាំសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ដោយឥតបង់ថ្លៃ រួមទាំងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតដែល ប.ស.ស. បានផ្តល់ជូន។





គួរបញ្ជាក់ផងដែរថា៖ ពិធីផ្សព្វផ្សាយនេះធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប នឹងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** ដោយមានការអញ្ជើញចូលរួមពីសំណាក់ លោក លោកស្រី តំណាងមន្ទីរ អង្គភាព និងស្ថាប័នពាក់ព័ន្ធនានា នៃ គ.ជ.ប សរុបប្រមាណជាង ៧០នាក់។

គួររំលឹកផងដែរថា កន្លងមករាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា បានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) ដែលក្របខ័ណ្ឌគោលនយោបាយនេះ គឺជាផែនទីបង្ហាញផ្លូវរយៈពេលវែង។ ប្រព័ន្ធគាំពារសង្គមផ្តោតលើ សសរស្តម្ភ សំខាន់ៗចំនួនពីរគឺ៖ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម៕













# នៅពេលឆាប់ៗខាងមុខនេះ បេឡាជាតិសន្តិសុខសង្គម នឹងដាក់ឲ្យអនុវត្តជាផ្លូវការនូវរបបសន្តិសុខសង្គមថ្មីផ្នែកប្រាក់សោធន



**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ក្នុងឱកាសអញ្ជើញជាអធិបតីបើកសិក្ខាសាលាស្តីពី "ការលើកកម្ពស់សុវត្ថិភាពចរាចរណ៍សម្រាប់កម្មករនិយោជិតកម្ពុជា" នាថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០បានថ្លែងថា៖ កន្លងមក ប.ស.ស. បានធ្វើការសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធជាច្រើនក្នុងការរៀបចំកម្មវិធីផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត អំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកសុវត្ថិភាពក្នុងការធ្វើដំណើរ សុវត្ថិភាពក្នុងការដឹកជញ្ជូនកម្មករនិយោជិតការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងជំរុញឲ្យប្រើប្រាស់រថយន្តដឹកអ្នកដំណើរដើម្បីដឹកជញ្ជូនកម្មករនិយោជិតព្រមទាំងមានការសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ចុះបណ្តុះបណ្តាល និងប្រឡងយកប័ណ្ណបើកបរ សម្របសម្រួលក្នុងការចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត(ឆៀក)និងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីលើកកម្ពស់សុវត្ថិភាពចរាចរណ៍លើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិតតាមគ្រប់រូបភាព។





**ឯកឧត្តម** បានបន្តទៀតថា៖ បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកជាឃាតករលាក់មុខដែលធ្វើឲ្យមនុស្សស្លាប់ របួស និងពិការ បានកើតឡើងជារៀងរាល់ថ្ងៃគួរឲ្យព្រួយបារម្ភក្នុងចំណោមនោះក៏មានកម្មករនិយោជិតដែលជាជនរងគ្រោះផងដែរ។ គ្រោះថ្នាក់ចរាចរណ៍បានបន្សល់ទុកនូវសោកនាដកម្មដ៏រន្ធត់ ដែលជាផលប៉ះពាល់ដល់សុខុមាលភាព សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គមជាតិទាំងមូល ចំពោះបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនេះ មិនអាចឲ្យក្រសួង ស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់តែឯងបានឡើយ វាជាបញ្ហារួមរបស់យើងទាំងអស់គ្នា។

យោងតាមរបាយការណ៍របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានឲ្យដឹងថា៖ គិតក្នុងឆមាសទី១ ឆ្នាំ២០២០នេះ ករណីគ្រោះថ្នាក់ចរាចរណ៍មកលើរថយន្តដឹកកម្មករនិយោជិតបានកើតឡើងចំនួន៨ករណី និងបង្កឲ្យមានជនរងគ្រោះចំនួន ២២៣នាក់ (ស្លាប់ចំនួន ២នាក់ របួសធ្ងន់ចំនួន ៣២នាក់ របួសស្រាលចំនួន ១៨៩នាក់) គ្រោះថ្នាក់កើតឡើងដោយរ៉ឺម៉កចំនួន ២ករណី ជនរងគ្រោះ ២នាក់ គ្រោះថ្នាក់កើតឡើងដោយកង់ចំនួន ៣ករណី ជនរងគ្រោះចំនួន ៣នាក់ និងគ្រោះថ្នាក់ដោយថ្មើរជើងមានចំនួន ១៨ករណី ជនរងគ្រោះចំនួន ១៨នាក់។









**ឯកឧត្តម** បានថ្លែងបញ្ជាក់ទៀតថា៖ ក្នុងនាមតំណាងថ្នាក់ដឹកនាំ នៃបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមកោតសរសើរ និងវាយតម្លៃខ្ពស់ក្នុងកិច្ចសហការរបស់អង្គការមូលនិធិបង្ការរបួសអាស៊ីប្រចាំកម្ពុជា (AIP) ដែលបានរួមចំណែកធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពក្នុងការធ្វើដំណើររបស់កម្មករនិយោជិត និងចូលរួមកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឲ្យស្ថិតនៅកម្រិតទាបដោយអនុលោមទៅតាមអនុសាសន៍របស់ **សម្តេចតេជោ ហ៊ុន សែន** "ថ្ងៃនេះ ថ្ងៃស្អែក កុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍"។ ហើយយើងខ្ញុំជឿជាក់ថា វគ្គសិក្ខាសាលានាថ្ងៃនេះ គឺពិតជាមានសារៈសំខាន់ក្នុងការពង្រឹងការទំនាក់ទំនង ជំរុញកិច្ចសហប្រតិបត្តិការ ព្រមទាំងបង្កើនសកម្មភាពរួមគ្នាទៅមុខជារៀងរហូត។

ជាមួយគ្នានេះដែរ **លោក គឹម បញ្ញា** នាយកអង្គការមូលនិធិបង្ការរបួសអាស៊ីប្រចាំកម្ពុជា (AIP) បានបញ្ជាក់ថា៖ អង្គការមូលនិធិបង្ការរបួសអាស៊ី (AIP) បានធ្វើការសហការជាមួយបេឡាជាតិសន្តិសុខសង្គមតាំងពីឆ្នាំ២០១៧ មកម្ល៉េះ ក្នុងការចូលរួមបង្កើន និងលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់បងប្អូនកម្មករនិយោជិត។

**លោក** ក៏បានថ្លែងការកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចសហការរបស់ ប.ស.ស. កន្លងមក ក្នុងកិច្ចខិតខំសង្គ្រោះជីវិតមនុស្សពីគ្រោះថ្នាក់ចរាចរណ៍ ជាពិសេសគឺបងប្អូនកម្មករនិយោជិតបានយល់ដឹងកាន់តែច្បាស់ស្តីពីសុវត្ថិភាពក្នុងការធ្វើដំណើរដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឲ្យមកនូវកម្រិតទាបបំផុត។

សូមបញ្ជាក់ថា៖ វគ្គសិក្ខាសាលាខាងលើ ប្រព្រឹត្តទៅនៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ ដែលមានការរៀបចំឡើងដោយ អង្គការមូលនិធិបង្ការរបួសអាស៊ីកម្ពុជា (AIP) ដែលមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន និងអង្គភាពដៃគូពាក់ព័ន្ធនានាសរុបប្រមាណជាង ៥០នាក់៕



# កិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹង កិច្ចគាំពារសង្គមដើម្បីឆ្លើយតបទៅនឹងជំងឺកូវីដ-១៩

នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ តំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃ ប.ស.ស. បានចូលរួមកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចគាំពារសង្គមដើម្បីឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ជាមួយប្រតិភូជាន់ខ្ពស់នៃអង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តម ម៉ម វណ្ណៈ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

កិច្ចប្រជុំពិភាក្សាខាងលើ មានគោលបំណងសំខាន់ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា និងដើម្បីឈ្វេងយល់ឲ្យបានកាន់តែលម្អិតអំពីការអនុវត្តរបបសន្តិសុខសង្គមលើផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព និងគម្រោងស្តីពីការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជននៅកម្ពុជា៕







# ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស នៃ ប.ស.ស. កម្ពុជា ចូលរួមកម្មវិធីស្តីពី "ខួបលើកទី២០ឆ្នាំ នៃការងារផ្នែកស្តារនីតិសម្បទា" តាមរយៈប្រព័ន្ធវីដេអូ (Video Conference)

ក្រោមការចាត់តាំងពី **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម **លោក ជៀក លីម៉េង** ប្រធានការិយាល័យស្តារនីតិសម្បទា នៃ ប.ស.ស. បានដឹកនាំមន្ត្រីបច្ចេកទេស នៃ ប.ស.ស.ចូលរួមកម្មវិធីស្តីពី "ខួបលើកទី២០ឆ្នាំ នៃការងារផ្នែកស្តារនីតិសម្បទា នៃរបបធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងារកូរ៉េ" តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលរៀបចំឡើងដោយអង្គភាពសំណងគ្រោះថ្នាក់ការងារ និងសុខុមាលភាព (COMWEL)នៃសាធារណរដ្ឋកូរ៉េ។

កម្មវិធីនេះ មានគោលបំណងផ្តោតសំខាន់លើការចែករំលែកបទពិសោធន៍នៃការអនុវត្តការងារស្តារនីតិសម្បទា របស់សមាជិកនៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) និងការបង្ហាញអំពីសមិទ្ធផលសម្រេចបានក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះនៃការអនុវត្តប្រកបដោយជោគជ័យលើការងារស្តារនីតិសម្បទានៅក្នុងរបបធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងាររបស់អង្គភាព COMWEL ព្រមទាំងការបង្កើតគណៈកម្មការផ្នែកស្តារនីតិសម្បទា នៃសមាគមសំណងគ្រោះថ្នាក់ការងារអាស៊ី (AWCA) ផងដែរ។

សូមបញ្ជាក់ថា កម្មវិធីនេះ មានការចូលរួមពីតំណាងបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រទេសជាសមាជិកសមាគម AWCA, តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ និងតំណាងអង្គការអន្តរជាតិខាងការងារ (ILO)ផងដែរ៕







# តើការបរិភោគចេកមុនចូលដេកនៅពេលយប់ អាចល្អយ៉ាងដូចម្ដេចខ្លះដល់សុខភាព?

ចេក គឺជាផ្លែឈើ ដែលសម្បូរទៅដោយសារធាតុចិញ្ចឹមហើយការបរិភោគផ្លែចេកទៀងទាត់រាល់ថ្ងៃនាំផលប្រយោជន៍ជាច្រើនដល់សុខភាព។

តាមឯកសារផ្សេងៗទៀតបានឲ្យដឹងថា បើគេបរិភោគចេកពេលយប់ប្រហែលមួយម៉ោងមុនចូលដេកពេលរាត្រី យើងទទួលបានផលប្រយោជន៍ច្រើន។ ខាងក្រោមនេះជាផលប្រយោជន៍នៃការបរិភោគចេកពេលយប់មុនចូលដេក៖

១.ចេកមានជាតិផ្អែម ឬជាតិស្ករដែលល្អដល់សុខភាព ផ្ដល់ថាមពលដល់លោកអ្នកឲ្យមានដំណេកល្អប្រសើរហើយមានកម្លាំងនៅពេលដែលអ្នកក្រោកពីដេក។ចេកសម្បូរដោយជាតិសរសៃ (Fiber) ដែលជួយដល់ការរំលាយអាហារ និងកាត់បន្ថយការទល់លាមក។ នៅពេលការរំលាយអាហារដំណើរការបានល្អ វាក៏ជួយឲ្យលោកអ្នកដេកបានស្រួលដែរ។

២.ចេកអាចជួយការស្រូបសារធាតុចិញ្ចឹមទ្រទ្រង់រាងកាយទាំងមូល។ ចេកសម្បូរម៉ាញ៉េស្យូម (Magnesium) និងប៉ូតាស្យូម (Potassium) ដែលរាងកាយយើងងាយស្រួលស្រូបយកសារធាតុទាំងនេះបើបរិភោគចេកនៅពេលយប់។

៣.ចេកមានសារធាតុ មេឡាតូនីន (Melatonin) ដែលអាចជួយឲ្យលោកអ្នកដេកលក់ស្រួល។ លោកអ្នកបរិភោគចេកយ៉ាងតិចបំផុតមួយម៉ោងមុនចូលដេកនឹងទទួលបានដំណេកល្អ។

៤.ចេកជួយកាត់បន្ថយការចុកដៃ ចុកជើង និងរមួលក្រពើនៅពេលយប់។ សារធាតុម៉ាញ៉េស្យូម និងប៉ូតាស្យូមនៅក្នុងចេកជួយការពារកុំឲ្យបញ្ហាទាំងនេះកើតឡើង។

តាមបទពិសោធន៍ជាក់ស្ដែង ការបរិភោគចេកពេលយប់ប្រហែលមួយម៉ោងមុនចូលដេក គឺនាំផលប្រយោជន៍ដល់ដំណេកល្អ និងសុខភាពជាទូទៅ។ លើសពីនោះទៀត បើលោកអ្នកបរិភោគចេកមួយផ្លែ ហើយទឹកឃ្មុំមួយស្លាបព្រាមុនចូលដេកក៏កាន់តែល្អប្រសើរដល់សុខភាព និងជួយឲ្យលោកអ្នកទទួលដំណេកបានកាន់តែល្អប្រសើរ។



# ភិក្ខុ វជិរប្បញ្ញោ គូ សុភាព "គំនិតអប់រំ"

ព្យាយាមបំពេញភារកិច្ចរបស់អ្នក ឲ្យអស់ពីសមត្ថភាព នៅថ្ងៃនេះ រឿងថ្ងៃស្អែក ចាំស្អែក ចាំជួប។

បើគេខុសអ្នកអាចជួយណែនាំគេដោយចិត្តមេត្តា តែកុំភ្លេចដុសខាត់សម្អាតចិត្តខ្លួនឯងផង។

ពេលអ្នកមិនខឹងច្រឡោតតប អ្នកបានឈ្នះមារទាំងខាងក្នុង ទាំងខាងក្រៅ។ អ្នកនៅតែដោះស្រាយតែដោះស្រាយដោយចិត្តនឹងធឹងលទ្ធផលនឹងបានគាប់ប្រសើរជាង។

ខឹងគេដុតខ្លួនឯង ខឹងកាន់តែយូរ ក្ដៅកាន់តែខ្លាំង។

គិតរឿងណាប្រាកដជារឿងហ្នឹង ស្មារតីឃាត់ចិត្តកុំឲ្យគិតច្របូកច្របល់ពេក។ រឿងណាហួសហើយ ឲ្យវាហួសទៅចុះ ហើយរឿងណាមិនទាន់មកដល់ ថ្ងៃស្អែកចាំជួបវា។

ពេលខឹង មនុស្សមិនសូវបានគិតវែងឆ្ងាយទេ ច្រើនគិតខ្លីនិយាយខុសបញ្ចេញកំហឹងសិនរួចទើបដេកស្ដាយក្រោយ។

រឿងមិនល្អបានកន្លងផុតទៅហើយ អ្នកអាចយកជាបទពិសោធន៍ តែកុំបណ្ដោយឲ្យវាមកដុតបំផ្លាញសេចក្ដីសុខក្នុងចិត្តអ្នកយូរពេក។

សន្សំលុយ សម្បូរលុយ សន្សំរឿង សម្បូររឿង សន្សំខឹង សម្បូរទុក្ខ។



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ : ៥០៤ ព.មប្រក

ថ្ងៃ ចន្ទ ៩ កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៩

# ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦/០៩/១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨/០៦/១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ /០៩/៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៤ ចុះថ្ងៃទី២៤ /០១/៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.បក ចុះថ្ងៃទី០៥/០៨/៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣/០៧/០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងប្រកាសរបស់ក្រសួងព័ត៌មានលេខ ៦២៥/០៩ ព.ម ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ "បេឡាជាតិរបបសន្តិសុខសង្គម" ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ។
- យោងលិខិតស្នើសុំផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់លោក ជាវ ប៊ុនរិទ្ធ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឲ្យផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ពីលោក ជាវ ប៊ុនរិទ្ធ មកលោក ហេង សុផាន់ណារិទ្ធ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៨៦៨២៨២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ មានអាសយដ្ឋាននៅផ្ទះ៧៣AE0E1 ផ្លូវ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជំនួសវិញ ៖
-មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅអាគារលេខ២០៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពី របបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាសយដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និងឈ្មោះអាសយដ្ឋានរោងពុម្ពនៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន និងចំនួន០២ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ។

**ប្រការ៣** : ករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤** : ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ខុទ្ទកាល័យ នៃក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ)
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មាន
  " ដើម្បីជូនជ្រាប "
- ឯកសារ - កាលប្បវត្តិ

# បេឡាជាតិសន្តិសុខសង្គម

**National Social Security Fund**


០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិសន្តិសុខសង្គម
NSSF Official
t.me/nssfcambodia
info@nssf.gov.kh
www.nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)


